ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ: ១៧៣/១៣.ន អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែវិច្ឆិកា ឆ្នាំ២០១៣
## និងទិសដៅការងារ ខែធ្នូ ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/១១/២០១៣ ដល់ ថ្ងៃទី ៣០/១១/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្រ្តពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម លើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងថែរក្សាបរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទីពា ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៥ នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុង **ខែវិច្ឆិកា ឆ្នាំ២០១៣** នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ពាក់ព័ន្ធ និងរបាយការណ៍ពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត រួមមាន : មន្ទីរប្រឆាំងគ្រឿងញៀន, រាជធានីភ្នំពេញ, ខេត្តព្រះសីហនុ, កណ្តាល, កំពង់ចាម, សៀមរាប, បាត់ដំបង, បន្ទាយមានជ័យ, ក្រចេះ, ប៉ៃលិន និង ខេត្តឧត្តរមានជ័យ ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបានក្នុងខែវិច្ឆិកានេះ បានកត់សំគាល់ឃើញមានបទល្មើសចរាចរគ្រឿងញៀនឆ្លងដែនប្រភេទ កូកាអ៊ីន ឆ្លងកាត់តាមច្រកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប បានកើតឡើងមួយករណីដែលធ្វើសកម្មភាពដោយបុរសជាជនជាតិហ្វីលីពីនម្នាក់ និងត្រូវបានសមត្ថកិច្ចប្រចាំការនៅទីនោះបង្ក្រាបទាន់ពេលវេលា និងដកហូតបានកូកាអ៊ីន ក្នុងចំនួនគួរកត់សំគាល់ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ , Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

# II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ១. អំពីការងារដឹកនាំ

### ១.១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

ដើម្បីចូលរួមចំណែកធ្វើឱ្យសម្រេច អាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ២០១៥ តាមការកំណត់ដោយប្រមុខដឹកនាំអាស៊ាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាន :

- អនុញ្ញាតជាគោលការណ៍ឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំកិច្ចប្រជុំប្រចាំឆ្នាំទ្វេភាគី-ត្រីភាគី កម្ពុជា វៀតណាម ឡាវ លើកទី១៣ របស់ខ្លួន ដើម្បីត្រួតពិនិត្យអំពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនរវាងប្រទេសទាំងបី ។
- អនុញ្ញាតជាគោលការណ៍ឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ទ្វេភាគី កម្ពុជា-ចិន ។

### ១.២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំបញ្ហាលើការងារជាគោលសំខាន់ៗ ជាអាទិ៍ :

- **អំពីគោលការណ៍ណែនាំ និងការដឹកនាំបញ្ហា** ឯកឧត្តមបានណែនាំអគ្គលេខាធិការដ្ឋាន រៀបចំសមាសភាពក្រុមការងារអន្តរក្រសួងសមាជិក អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាថ្មី, ផ្តល់សមាសភាពសមាជិកជាថ្មីនៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ និង សមាជិកថ្មីនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ។ ជាមួយនេះ ឯកឧត្តមបានឯកភាពជាគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរជាតិទៅទស្សនកិច្ចសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន, បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាលក្នុងការរៀបចំវគ្គបណ្តុះបណ្តាល បំប៉ន ស្តីពីការព្យាបាល ការថែទាំ និងការផ្តល់ប្រឹក្សាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ និងការពិនិត្យលទ្ធភាពដើម្បីប្រែក្លាយ"មណ្ឌលបណ្តុះបណ្តាលជនពិការស៊ីវិល្ល"នៅខេត្តបន្ទាយមានជ័យ ទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទូទៅសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនដែលបានព្យាបាលធូរស្រាល ព្រមទាំងបានណែនាំឱ្យពិនិត្យបានហ្មត់ចត់ចំពោះសំណើសុំបន្តកម្មវិធីម្ទុល/ស៊ីរាំង លើកទី៩ របស់អង្គការមិត្តសំឡាញ់ ។

  **ជាមួយនេះ** ឯកឧត្តមបានឯកភាពឱ្យបន្តចុះធ្វើអភិបាលកិច្ចនៅសាលានគរបាលភូមិភាគ២, ភូមិភាគ៦, ភូមិភាគ៥ និង សាលានគរបាលភូមិភាគ៤ រួមទាំងការរៀបចំពិធីប្រគល់សម្ភារៈសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀនដល់បណ្ឌិត្យសភានគរបាលកម្ពុជា និងត្រៀមលក្ខណៈរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងលើកទិសដៅការងារ ឆ្នាំ២០១៤ ។

- **អំពីកិច្ចសន្ទនាការជាមួយភ្ញៀវជាតិ និង អន្តរជាតិ** ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ ប៊ូ ចាងហ្គួ (Bu Jianguo) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃស្ថានឯកអគ្គរដ្ឋទូត

សាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅកម្ពុជា កាលពីថ្ងៃទី០៧/១១/២០១៣ ។ តាមរយៈ កិច្ចពិភាក្សាការងារនេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីនឹងអញ្ជើញទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី១៦ ដល់ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៣ លើការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

- **អំពីលិខិតបទដ្ឋានគតិយុត្តិ** ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីបានណែនាំឱ្យជំរុញការពិនិត្យលើសេចក្តីព្រាង "គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តន៍ច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់"និង"គោលនយោបាយ និង គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធី ម្ជុល/ស៊ីរ៉ាំង នៅកម្ពុជា" ឱ្យបានឆាប់រហ័ស ។

ជាមួយនេះ ឯកឧត្តមបានណែនាំឱ្យជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការពិនិត្យកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិ ឱ្យស្របទៅនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ថ្មី) ។

## ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពី ខែតុលាឆ្នាំ២០១៣ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### ២.១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័ន ជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ សប្តាហ៍ ខែ, ការអប់រំតាមសហគមន៍ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

**ដោយឡែក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បាន :

- ចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន <u>១</u> រូប ជាសមាជិកនៃគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ។
- ចូលរួមជាកិត្តិយស ដោយឯកឧត្តមអគ្គលេខាធិការ នៅក្នុងពិធីបើកមហោស្រពតន្ត្រី និងចម្រៀងកុមារ ពានរង្វាន់ក្រសួងព័ត៌មាន ឆ្នាំ២០១៣ (០១/១១/២០១៣) ។
- បានបញ្ជ្រាបខ្លឹមសារអប់រំពីគ្រឿងញៀន ទៅក្នុងកម្មវិធីប្រគំតន្ត្រីស្រុកស្រែ នៅខេត្តស្វាយរៀង មានមហាជនចូលរួម **<u>២១.000</u>** នាក់ ។
- ចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួមជាវាគ្មិន ផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់សាស្ត្រាចារ្យ បុគ្គលិកសិក្សា និស្សិតបង្គោល នៃសាកលវិទ្យាល័យឡាយហ្វ នៅខេត្តព្រះសីហនុ សរុបចំនួន **<u>២៣៤</u>** នាក់ (២៩/១១/២០១៣) ។
- ចូលរួមតាមការអញ្ជើញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពិធីផ្តល់ប័ណ្ណសរសើរជូនដល់ រោងចក្រ សហគ្រាស និង គ្រឹះស្ថាន ដែលមានស្នាដៃល្អក្នុងការងារប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅកន្លែងធ្វើការ ប្រចាំឆ្នាំ២០១៣ (២៦/១១/២០១៣) ។

**ការងារក្រៅប្រទេស :** អគ្គលេខាធិការដ្ឋាន បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ និងសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីបញ្ជូនមន្ត្រីជំនាញ (សរុបចំនួន ៣ រូប) ទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពី យុទ្ធសាស្ត្រអប់រំបង្ការការប្រើប្រាស់គ្រឿងញៀន កាលពីថ្ងៃទី២៦-២៨/១១/២០១៣ នៅទីក្រុងណាននីង ប្រទេសចិន ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ និងបណ្តុះបណ្តាលជនបង្គោលនៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ៥ គឺ ខេត្តបាត់ដំបង, ខេត្តស្វាយរៀង, ខេត្តព្រះសីហនុ, ខេត្តកំពង់ស្ពឺ និង ខេត្តតាកែវ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួម *៧៧.៩០៥ នាក់* លើ **៦៤.៦៦៧** នាក់ នៃខែតុលា ឆ្នាំ២០១៣ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

## ២.២. *ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែវិច្ឆិកាឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តន៍នៅតែបន្តយកចិត្តទុកដាក់ចូលរួមសហការបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### *ក. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន*

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤៨** ករណី លើ ៥៥ ករណី នៃខែតុលា ឆ្នាំ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **១០៤** នាក់ លើ ១១៥ នាក់ នៃខែតុលា ឆ្នាំ២០១៣ ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **១០៤** នាក់ ខាងលើ មានប្រុស ៩០ នាក់ ស្រី ១៤ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ ៩៩** នាក់ (ស្រី ១៣ នាក់), **វៀតណាម** ៣ នាក់ (ស្រី ១ នាក់), **អេស្ប៉ាញ** ១ នាក់ (ប្រុស), **ហ្វីលីពីន** ១ នាក់ (ប្រុស) ត្រូវសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត។
- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីនគ្រាប់ (WY) ៦៨៤,៧៤ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១៤០,២៥ ក្រាម, កូកាអ៊ីន ៣.២០០ ក្រាម, កញ្ឆា ២៩,២០ ក្រាម និង ៥២ ដើម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក រួមមាន :** ម៉ូតូ ០៩ គ្រឿង, រថយន្ត ០៣ គ្រឿង, ប្រាក់រៀល ៦៦០.២០០ រៀល, ប្រាក់អាមេរិក ២៤៣ ដុល្លារ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី២** ។

ដោយឡែក ជនសង្ស័យចាប់តាមដីកា មាន ៣ ដីកា = មនុស្ស ៣ នាក់ (ស្រី ១ នាក់) ជនជាតិខ្មែរ ។

### *ខ. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង **ខែវិច្ឆិកា ឆ្នាំ២០១៣** នេះ មានដូចខាងក្រោម :

- សារធាតុគីមី គិតជា គីឡូក្រាម ចំនួន ៤.០២២.៧៩៨ គ.ក្រ និង ៣.៥៩៨ លីត្រ
- វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទចំនួន ១២ គ.ក្រ និង ៧៨៧ ក្រាម **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២**

### ត. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែវិច្ឆិកានេះ សរុបបានចំនួន ២២ ករណី = ២៤ សំណាក **វិជ្ជមានសារធាតុញៀនទាំង** ២៤ សំណាក = ១០០ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២០ សំណាក = ៨០ % -មេតំហ្វេតាមីនគ្រាប់ (WY) ០២ សំណាក = ១០ %

-កូកាអ៊ីន ០២ សំណាក = ១០ %

### ២.៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

### ក. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់

**ការងារក្នុងប្រទេស**

- បានចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញលើសេចក្តីព្រាងរបាយការណ៍អំពីច្បាប់ និងគោលនយោបាយស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ កាលពីថ្ងៃទី០៤/១១/២០១៣ ដើម្បីក្តាប់បានបញ្ហាពាក់ព័ន្ធគ្រឿងញៀន ។
- ចូលរួមជាវាគ្មិន តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីផ្តល់បទបង្ហាញពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅក្នុងវគ្គបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធស្តីពីការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈកម្មវិធីដៃគូសហគមន៍ នៅខេត្តពោធិ៍សាត់ (០៦-០៨/១១/២០១៣) អ្នកចូលរួម **៧៣** នាក់, ខេត្តកំពង់ឆ្នាំង (១៣-១៥/១១/២០១៣) អ្នកចូលរួម **៨៣** នាក់, ខេត្តសៀមរាប (២០-២២/១១/២០១៣) អ្នកចូលរួម **៦៦** នាក់ (សរុប **២២២** នាក់) ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមកិច្ចប្រជុំអ្នកពាក់ព័ន្ធដើម្បីពិភាក្សាលើប្រធានបទស្តីពី បច្ចុប្បន្នភាពនៃគោលនយោបាយគ្រឿងស្រវឹង តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព កាលពីថ្ងៃទី០៨/១១/២០១៣ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ០១ រូប ទៅចូលរួមក្នុងកិច្ចប្រជុំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី១៥/១១/២០១៣ ដើម្បីសម្របសម្រួលការងារមួយចំនួនមុនការចេញដំណើររបស់គណៈប្រតិភូកម្ពុជា ទៅចូលរួមសន្និសីទអន្តរជាតិ លើកទី១១ ស្តីពីបញ្ហាអេដស៍ក្នុងតំបន់ អាស៊ី-ប៉ាស៊ីហ្វិក ។
- បានអនុញ្ញាតឱ្យអង្គការមិត្តសំឡាញ់ បន្តអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំង រយៈពេល១ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ **០១** រូប និងសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីចំនួន **០២** រូប ទៅទស្សនកិច្ចសិក្សាស្តីពីការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនប្រភេទ ATS នៅទីក្រុងបាងកក និង ខេត្តឈុនបុរី ប្រទេសថៃ (១១-១៦/១១/២០១៣) ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ **០២**រូប ទៅចូលរួមកិច្ចប្រជុំអន្តរជាតិ ស្តីពីបញ្ហាអេដស៍ក្នុងតំបន់អាស៊ី

អាស៊ី-ប៉ាស៊ីហ្វិក លើកទី១១ កាលពីថ្ងៃទី១៨-២២/១១/២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។

### *ខ. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម*

**ការងារក្នុងប្រទេស**

- បានចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលដល់មន្ត្រីក្រសួងសុខាភិបាល និងមន្ត្រីសុខាភិបាលពន្ធនាគារ ស្តីពីសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ដូចតទៅ :
  - សម្រាប់គ្រូពេទ្យព្យាបាល ខេត្តបាត់ដំបង ថ្ងៃទី០៤-០៨/១១/២០១៣ ចំនួន ៣៣ នាក់
  - សម្រាប់គ្រូពេទ្យព្យាបាល ខេត្តព្រះសីហនុ ថ្ងៃទី២៥-២៩/១១/២០១៣ ចំនួន ៣២ នាក់
  - សម្រាប់គិលានុបដ្ឋាក-យិកា ខេត្តព្រះសីហនុ ថ្ងៃទី០៤-០៨/១១/២០១៣ ចំនួន ៣៣ នាក់
  - សម្រាប់គិលានុបដ្ឋាក-យិកា ខេត្តសៀមរាប ថ្ងៃទី២៥-២៩/១១/២០១៣ ចំនួន ៣៣ នាក់

  **(សរុប ១៣១ នាក់)**

### *២.៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់*

**ការងារក្នុងប្រទេស**

- បានរៀបចំពិធីប្រគល់សម្ភារៈសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ដល់បណ្ឌិត្យសភានគរបាលកម្ពុជា កាលពីថ្ងៃទី០៦/១១/២០១៣ ។
- បានរៀបចំពិធីប្រគល់សម្ភារៈសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដល់ការិយាល័យ BLO ចំនួន ៥ កន្លែងនៅ ច្រកទ្វារជ្រៃធំ (ខេត្តកណ្តាល), ច្រកទ្វារប៉ោយប៉ែត (ខេត្តបន្ទាយមាន ជ័យ), ច្រកទ្វារចាំយាម (ខេត្តកោះកុង), ច្រកទ្វារព្រំ (ខេត្តប៉ៃលិន) និង ច្រកទ្វារដូង (ខេត្តបាត់ដំបង) កាលពីថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៣ (សម្ភារៈមាននៅក្នុងឧបសម្ព័ន្ធទី២) ។
- បានបន្តចុះធ្វើអភិបាលកិច្ចនៅសាលានគរបាលភូមិភាគ២ (ខេត្តកំពង់ចាម ១០-១២/១១/២០១៣), សាលានគរបាលភូមិភាគ៦ (ខេត្តកំពង់ឆ្នាំង ១៤-១៦/១១/២០១៣), សាលានគរបាលភូមិភាគ៥ (ខេត្តបាត់ដំបង ០៦-០៧/១១/២០១៣), សាលានគរបាលភូមិភាគ៤ (ខេត្តសៀមរាប ១៣-១៥/១១/ ២០១៣) ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ **១** រូប ជាតំណាងអគ្គលេខាធិការដ្ឋាន ចូលរួមក្នុងពិធីបិទវគ្គបំប៉នជំនាញមន្ត្រីនគរបាលយុត្តិធម៌ កាលពីថ្ងៃទី១២-១៣/១១/២០១៣ (សិក្ខាកាម **១៨០** នាក់) ។
- បានរៀបចំកិច្ចប្រជុំ លើកទី៥ នៃគណៈកម្មការប្រឹក្សាយោបល់គម្រោង "ភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន" (PATROL) ដើម្បីរៀបចំផែនការសកម្មភាពគម្រោង ដែលត្រូវអនុវត្តបន្តនៅក្នុងឆ្នាំ២០១៤ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ (សមាសភាព **១៦** រូប) ។
- បានរៀបចំវគ្គបណ្តុះបណ្តាលពីវិធីគ្រប់គ្រង និងបញ្ចូលទិន្នន័យ ក្នុងគេហទំព័រ របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិ ដល់មន្ត្រីមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ចំនួន ៣ រូប កាលពីថ្ងៃទី២៥-២៨/១១/២០១៣ ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ៣ រូប ចូលរួមសិក្ខាសាលាស្តីពីការអភិវឌ្ឍលេខសំគាល់អត្តសញ្ញាណ

( **U**nique **I**dentifier **C**ode . UIC) សម្រាប់ក្រុមជនងាយរងគ្រោះ នៅកម្ពុជា តាមការអញ្ជើញរបស់ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) ថ្ងៃទី២៧/១១/ ២០១៣ នៅរាជធានីភ្នំពេញ ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ និងសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីចំនួន **៥** រូប ដែលជាក្រុមការងារសម្របសម្រួលកណ្តាលនៃគម្រោង PATROL ទៅចូលរួមសិក្ខាសាលាអនុតំបន់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន សម្រាប់បណ្តាប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ កាលពីថ្ងៃទី០៤/១១/ ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ០១ រូប ទៅចូលរួមកិច្ចប្រជុំអនុតំបន់ស្តីពី ការត្រួតពិនិត្យការធ្វើពាណិជ្ជកម្មសារធាតុបំផ្លាញស្រទាប់អូហ្សូន កាលពីថ្ងៃទី២៦-២៨/១១/២០១៣ នៅប្រទេសឡាវ ។

**ដោយឡែក**

- **ក្រសួងការពារជាតិ** បានរៀបចំ :
  - ✓ កិច្ចប្រជុំអន្តរស្ថាប័ន ដើម្បីពិនិត្យលើខ្លឹមសារសេចក្តីព្រាងឯកសារ វិវេចនាយុទ្ធសាស្ត្រការពារជាតិ ឆ្នាំ២០១៣ កាលពីថ្ងៃទី២១/១១/២០១៣ ។
  - ✓ រៀបចំធ្វើបច្ចុប្បន្នភាពសមាជិកនៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ** បានចាត់មន្ទីរប្រឆាំងគ្រឿងញៀនជាតំណាងដឹកនាំគណៈប្រតិភូ ចំនួន **១៧** រូប ទៅចូលរួមកិច្ចប្រជុំ ជាមួយនាយកដ្ឋានបង្ការ បង្ក្រាបគ្រឿងញៀន នៃបញ្ជាការដ្ឋានកងទ័ពការពារព្រំដែន (វៀតណាម) ស្តីពីកិច្ចសហប្រតិបត្តិការបង្ការ និងបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែនតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-វៀតណាម កាលពីថ្ងៃទី១៩-២២/១១/២០១៣ នៅទីក្រុងហូជីមិញ ។

### *២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ*

ខែវិច្ឆិកា ឆ្នាំ២០១៣ នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ប្រទេសក្នុង អនុតំបន់ តំបន់ និង អន្តរជាតិ មានដូចខាងក្រោម :

**ការងារក្នុងប្រទេស** បានចាត់បញ្ជូនតំណាង ០១ រូប ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការចម្រុះសហប្រតិបត្តិការកម្ពុជា-វៀតណាម លើក ទី១៣ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស កាលពីថ្ងៃទី២៦-២៧/១១/ ២០១៣ តាមការអញ្ជើញរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**ការងារក្រៅប្រទេស**

- បានរៀបចំបញ្ជូនគណៈប្រតិភូមានសមាសភាពចំនួន **៦** រូប ដឹកនាំដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ទៅចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ចិន លើកទី៤ កាលពីថ្ងៃទី០៤-០៨/ ១១/២០១៣ នៅទីក្រុង ZhengZhou ខេត្ត Hainan ប្រទេសចិន ដើម្បីពិនិត្យពិភាក្សា និងវាយតម្លៃការអនុវត្តកិច្ចសហប្រតិបត្តិការកន្លងមក និងលើកទិសដៅសម្រាប់ការអនុវត្តបន្តនៅបណ្តាឆ្នាំខាងមុខ ។

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមកិច្ចប្រជុំពិភាក្សាគោលនយោបាយក្រៅផ្លូវការអាស៊ីអាគ្នេយ៍ លើកទី៩ ស្តីពីគ្រឿងញៀននិងការអភិវឌ្ឍក្នុងតំបន់អាស៊ីអាគ្នេយ៍ កាលពីថ្ងៃទី២៧-២៨/១១/២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។

***ការងារផ្សេងៗ :***

អគ្គលេខាធិការដ្ឋាន បាននិងកំពុងបន្តការរៀបចំសមាសភាពក្រុមការងារអន្តរក្រសួងសមាជិក អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាថ្មី សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែធ្នូ ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. សំណើសុំឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដើម្បីផ្តល់ការគាំទ្រលើរបាយការណ៍សង្ខេបស្តីពីលទ្ធផលរបស់ការសិក្សាថ្នាក់ជាតិ ការធ្វើអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍, ឥរិយាបថប្រឈមរបស់ពួកគេ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា ។

១.២. ត្រៀមចូលរួមជាវាគ្មិន នៅក្នុងកិច្ចប្រជុំតុមូលតាមវិទ្យុ ហ្វេស.អឹម ១០២ ក្រោមប្រធានបទ កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀននៅកម្ពុជា (០៣/១២/២០១៣) ។

១.៣. ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធីសភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី អំពីសកម្មភាពនិងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន នៅក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ (ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣) ។

១.៤. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៥. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ។

១.៦. ចាត់បញ្ជូនមន្ត្រីជំនាញ ទៅចូលរួមធ្វើបទឧទ្ទេសនាមពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅសាកលវិទ្យាល័យស្វាយរៀង (ថ្ងៃទី០៣/១២/២០១៣), សាកលវិទ្យាល័យជាស៊ីមកំចាយមារ (ព្រៃវែង ថ្ងៃទី០៤/ ១២/២០១៣), សាកលវិទ្យាល័យបាត់ដំបង (ថ្ងៃទី១១/១២/២០១៣), សាកលវិទ្យាល័យមានជ័យ (ខេត្តបន្ទាយមានជ័យ ថ្ងៃទី១២/១២/២០១៣) និង សាកលវិទ្យាល័យអង្គរ (ខេត្តសៀមរាប ថ្ងៃទី១៣/១២/ ២០១៣) ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយមន្ទីរប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងគ្រឿងញៀនខេត្តស្ទឹងត្រែង ដើម្បីបន្តការស្រាវជ្រាវរកខ្សែរយៈទាក់ទងផ្សេងទៀត ពាក់ព័ន្ធករណីចាប់មេតំហ្វេតាមីន ICE កាលពីថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៣ ចំនួន ១.៨១១,៧ ក្រាម ។

២.២. សហការសម្របសម្រួលជាមួយកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀនកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ដើម្បីបន្តការស្រាវជ្រាវរកខ្សែរយៈទាក់ទងផ្សេងទៀត ពាក់ព័ន្ធនឹងករណីឃាត់ខ្លួនជនជាតិឡាវពីរនាក់ ជាមួយមេតំហ្វេតាមីន ICE ចំនួន ១.៩៥៥,៩ ក្រាម កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០១៣ ។

២.៣. បន្តសហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

២.៤. បន្តសហការជាមួយអង្គការ UNODC ដើម្បីដំណើរការវិភាគឱ្យបានច្បាស់លាស់ពីរុក្ខជាតិវល្លិ៍រមៀត ដែលសង្ស័យថាមានផ្ទុកសារធាតុគីមីផ្សំសម្រាប់កែច្នៃផលិតជាគ្រឿងញៀនខុសច្បាប់ ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ត្រៀមលក្ខណៈជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ (ថ្ងៃទី០១/១២/២០១៣) ។

៣.២. បន្តចូលរួមក្នុងវគ្គបណ្តុះបណ្តាល សម្រាប់មន្ត្រីក្រសួងសុខាភិបាល និងមន្ត្រីសុខាភិបាលពន្ធនាគារ ស្តីពីសុខភាពផ្លូវចិត្ត និងគ្រឿងញៀន នៅខេត្តសៀមរាប និង ខេត្តកំពង់ចាម ។

៣.៣. ត្រៀមលក្ខណៈជូនអគ្គលេខាធិការ អញ្ជើញជាគណៈអធិបតី និងមានមតិសំណេះសំណាលនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពី ការសិក្សាស្រាវជ្រាវពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀននៅកម្ពុជា ធ្វើនៅខេត្តសៀមរាប (ថ្ងៃទី០៣/១២/២០១៣) និង នៅរាជធានីភ្នំពេញ (ថ្ងៃទី០៦/១២/២០១៣) ។

៣.៤. ត្រៀមចូលរួមធ្វើបទឧទ្ទេសនាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការឆ្លើយតបនឹងមេរោគអេដស៍ / ជំងឺអេដស៍ តាមរយៈដៃគូសហគមន៍ក្នុងចំណោមក្រុមប្រឈមខ្ពស់ (នៅខេត្តស្ទឹងត្រែង ថ្ងៃទី២៤-២៦/១២/២០១៣) ។

៣.៥. រៀបចំគម្រោងសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធផ្នែកព្យាបាល និង ផ្នែកស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគម្រោងតម្រូវការសម្ភារៈ ឱសថ ដែលត្រូវផ្តល់ដោយភាគីវៀតណាម ។

៣.៦. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៧. បន្តពិនិត្យលើសេចក្តីព្រាង "គោលនយោបាយ និងគោលការណ៍ណែនាំស្តីពី ការអនុវត្តកម្មវិធី ម្តុល/ស៊ីរ៉ាំង នៅកម្ពុជា និង គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.៨. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៩. បន្តពង្រឹងសមត្ថភាពការងារព្យាបាលដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាលដែលមានស្រាប់ (មន្ទីរពេទ្យបង្អែក-មណ្ឌលសុខភាព) នៅទូទាំងប្រទេស ដោយយកបទពិសោធន៍តាមខេត្តបន្ទាយមានជ័យ និងខិតខំសហការសម្របសម្រួលលើការងារបាលអ្នកញៀនគ្រឿងញៀននៅតាមប៉ុស្តិ៍សុខភាពពន្ធនាគារ ។

៣.១០. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពី កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែន កម្ពុជា-វៀតណាម ដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន ១៥ រូប មកពីច្រកទ្វារ បាវិត, ភ្នំដិន, ព្រៃធំ, ក្អមសំណ, ត្រពាំងផ្លុង ពីថ្ងៃទី០២-០៦/១២/២០១៣ នៅស្នាក់ការនគរបាលព្រំដែន ក្រុងបាវិត ខេត្តស្វាយរៀង ។

៤.២. ចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ ០១ រូប ចូលរួមជាភ្ញៀវកិត្តិយសនិងជាវាគ្មិនក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីគម្រោងសហគមន៍ស្វែងការគាំទ្រសម្រាប់កាត់បន្ថយគ្រោះថ្នាក់ពីមេរោគអេដស៍/ជំងឺអេដស៍ ការប្រើប៉ាវគ្រឿងញៀន និង ការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ថ្ងៃទី០៣-០៥ និងថ្ងៃទី១១-១៣/១២/២០១៣ នៅនាយកដ្ឋានបុគ្គលិក ក្រសួងមហាផ្ទៃ ។

៤.៣. បន្តកិច្ចសហការជាមួយអង្គការFHI360 ក្នុងការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

៤.៤. សហការសម្របសម្រួល និងជំរុញដំណើរការការងាររបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ និងរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលនៅទីនោះ ។

៤.៥. សហការជាមួយអង្គការ FHI360 រៀបចំកិច្ចប្រជុំតុមូល ដើម្បីពិភាក្សាបន្តលើកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៤.៦. បន្តការចូលរួមធ្វើបទឧទ្ទេសនាមអំពីសភាពការណ៍គ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ។

៤.៧. ត្រៀមរៀបចំពិធីប្រគល់-ទទួល សម្ភារៈមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ពី អង្គការ FHI360 ។

៤.៨. បន្តកិច្ចសហការជាមួយអង្គការ FHI360 ចុះធ្វើអភិបាលកិច្ចនៅសាលានគរបាល ភូមិភាគ១ និងភូមិភាគ៣ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមលក្ខណៈជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន (១៦-២០/១២/២០១៣) ។

៥.២. ត្រៀមរៀបចំកិច្ចប្រជុំ ត្រីភាគី ទ្វេភាគី ថ្នាក់រដ្ឋមន្ត្រី ប្រទេសកម្ពុជា វៀតណាម ឡាវ (ថ្ងៃទី១០-១៣/១២/២០១៣) ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- បន្តត្រួតពិនិត្យ និងរៀបចំទិន្នន័យនៃការប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា សម្រាប់ត្រៀមធ្វើការផ្សព្វផ្សាយជាផ្លូវការ ។
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការជាតិ ៣ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ថ្ងៃទី០៤/១២/២០១៣) ។
- បន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ធ្វើបច្ចុប្បន្នភាព គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ឆ្នាំ២០១៣ ។
- បន្តធ្វើបច្ចុប្បន្នភាព លើបញ្ជីសារពើភណ្ឌសម្ភារៈគម្រោង CMBF14 ។
- រៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ។
- ត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាលើប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិ នៅក្នុងពិធីប្រកាសផ្ទេរតំណែង អគ្គលេខាធិការ អ.ជ.ប.គ.ញ កាលពីថ្ងៃទី៣១ ខែ តុលា ឆ្នាំ ២០១៣ ។
- ចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ០១ រូប និង មន្ត្រីថ្នាក់បច្ចេកទេស ០១ រូប ទៅចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេស នៅថ្ងៃ ទី០៣-០៤/១២/២០១៣ នៅខេត្តបាត់ដំបង និងកិច្ចប្រជុំកម្រិតខ្ពស់ នៅសណ្ឋាគារកាំបូឌីយ៉ាណា ថ្ងៃទី០៩/១២/ ២០១៣ ដើម្បីពិភាក្សាលើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ។
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ ២០១៤ ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក មាស_វីរិទ្ធ

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"**ដើម្បីជូនប្រាប**"

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"**ដើម្បីចុះការ**"

-ឯកសារ